# ព្រះបានប្រទានផ្លូវសម្រាប់ថ្ងៃនេះ

...សូមបន្តិចទៀតក្នុងកាលយើងកំពុងអោនក្បាលចុះ។

ព្រះវរបិតានៃស្ថានសួគ៌របស់យើង យើងអរព្រះគុណទ្រង់សម្រាប់ព្រះយេស៊ូវគ្រីស្ទ ការសន្យាដ៏អស្ចារ្យរបស់ទ្រង់ដែលទ្រង់បានប្រទានដល់យើង។ យើងខ្ញុំសូមអរព្រះគុណទ្រង់ចំពោះការទាំងអស់នេះ។ យើងស្ថិតនៅក្រោមការរំពឹងទុកដ៏អស្ចារ្យនៅទីនេះនៅក្នុងទីក្រុងនេះក្នុងចំណោមគ្រីស្ទានដ៏ល្អទាំងនេះ។ យើងរំពឹងថានឹងឃើញទ្រង់ធ្វើការក្នុងចំណោមពួកយើង បង្ហាញវត្តមានរបស់ទ្រង់ ផ្តល់ឱ្យមនុស្សនូវសេចក្តីជំនឿ បំផុសគំនិតពួកគេឱ្យជឿ។ នោះជាគោលបំណងរបស់យើងក្នុងការមកទីនេះ ព្រះបិតា។ យើងដឹងថាយើងអាចទុកចិត្តទ្រង់។ យើងនឹងមិនខកចិត្តឡើយ។ ដ្បិតយើងសូមក្នុងព្រះនាមទ្រង់។ អាម៉ែន។

សូមអង្គុយចុះ។

ព្រឹកនេះខ្ញុំសប្បាយចិត្តណាស់ដែលបានញ៉ាំអាហារពេលព្រឹកជាមួយក្រុមអ្នកបម្រើព្រះល្អៗទាំងនេះនៅក្នុងទីក្រុង។ ដូច្នេះហើយយើង...ខ្ញុំគិតថា—បងប្អូនបានថតវាប្រសិនបើនរណាម្នាក់ចង់បាន។ គ្រានៃការប្រកបបែបនេះដែលយើងមាន។ ហើយឥឡូវនេះ យប់នេះជាយប់ទីពីររបស់យើង ដែលកំពុងធ្វើដំណើរតាមផ្លូវ។ ដូច្នេះឥឡូវនេះ យើងទុកចិត្តថា ព្រះអម្ចាស់នឹងប្រទានពរអ្នកទាំងអស់គ្នាយ៉ាងបរិបូរណ៍។

ខ្ញុំជឿថាខ្ញុំកំពុងសម្លឹងមើលមិត្តល្អរបស់ខ្ញុំគឺលោកស្រី អាប់ស្ទួ ដែលអង្គុយនៅទីនេះ បងស្រីអាប់ស្ទួ។ សូមព្រះអម្ចាស់ប្រទានពរអ្នក។ ខ្ញុំចាំបងប្រុស វីលី អាប់ស្ទួ។ ខ្ញុំទទួលសំបុត្រពីនាងនៅថ្ងៃមុន និងរូបភាពរបស់បងប្រុសវីលីសមាជិកសភា។ ដូច្នេះគាត់—គាត់បានពិការអស់រយៈពេលហុកសិបប្រាំមួយឆ្នាំមកហើយ។

កាលបានប្រជុំនៅយប់មួយ ឃើញនិមិត្តមួយអំពីគាត់ អង្គុយ ឆ្លងកាត់ទស្សនិកជន ជាមួយនឹងឈុតខោអាវរបស់គាត់ ក្រាបចុះ។ គាត់បានជិះរទេះរុញ និងកាន់ឈើច្រត់ ដូចដែលអ្នកទាំងអស់គ្នាធ្លាប់ស្គាល់គាត់ ព្រ ះអម្ចាស់យេ

ស៊ូវបានព្យាបាលគាត់នៅយប់ដដែលនោះ។ ហើយគាត់មានជំនឿរហូតដល់គាត់ស្លាប់។

យើងមានកិត្តិយសណាស់ យប់នេះសម្រាប់ស្ត្រីមេម៉ាយជាប្រពន្ធរបស់គាត់ដែលបានអង្គុយនៅទីនេះ។ តើគាត់មានអាយុប៉ុន្មានពេលទៅជួបព្រះអម្ចាស់? តើគាត់មានអាយុប៉ុន្មាន? [បងស្រីអាប់ស្លូឆ្លើយ—អេដ។] រស់នៅបានអាយុប៉ែតសិបប្រាំមួយឆ្នាំ។ [បងស្រីអាប់ស្លូថ្លែងទីបន្ទាល់អំពីការស្លាប់របស់គាត់។] បានទៅឋានសួគ៌ដើម្បីនៅជាមួយ...យើងមានអំណរគុណចំពោះបុរសដ៏អស្ចារ្យ អ្នកចម្បាំងនៃសេចក្តីជំនឿដ៏អស្ចារ្យ។

ឥឡូវនេះ យប់នេះ យើងមិនចង់ទុកអ្នកយូរទេ។ យើងទុកអ្នកលើសដប់នាទីកាលពីល្ងាចម្សិល ម្ភៃនាទីរហូតដល់ម៉ោងដប់។ ជាធម្មតាយើងចេញនៅម៉ោងប្រាំបួនសាមសិប។ ខ្ញុំនឹងព្យាយាមកំណត់ពេលសម្រាប់យប់នេះ។ ខ្ញុំបាន...ខ្ញុំបានផ្លាស់ប្តូរពីសារទំនាយរបស់ខ្ញុំ ដែលខ្ញុំបានអធិប្បាយជុំវិញតំបន់ផ្សេងៗនៃប្រទេស ទៅកាន់កម្មវិធីផ្សាយដំណឹងល្អម្តងទៀត។ ហើយនៅលើសារទំនាយទាំងនោះ យើងនឹងរក្សាវាបន្ត។ ហើយឥឡូវនេះដើម្បីកាត់វាចុះ វារៀងលំបាកបន្តិចហើយវាផ្លាស់ប្តូរ—ព័ន្ធកិច្ចទាំងអស់គ្នា។

ហើយមូលហេតុដែលខ្ញុំធ្វើបែបនេះ ៈ ព្រោះថ្ងៃមួយចុះមកពីប្រទេសកាណាដា នៅខាងលើនៅម៉ុនតាណា ព្រឹកព្រលឹមមួយ ព្រះអម្ចាស់យេស៊ូវ...ខ្ញុំដឹងថាស្តាប់ទៅចម្លែក ប៉ុន្តែខ្ញុំកំពុងជិះឡាន ហើយមានអ្វីមួយទាក់ទាញចំណាប់អារម្មណ៍ខ្ញុំ។ ខ្ញុំបានឮសំឡេងធម្មតាដូចអ្នកឮខ្ញុំនិយាយថា "ឈ្មោះរបស់អ្នកត្រូវបានសរសេរនៅលើភ្នំនោះ។" ហើយខ្ញុំបានមើលទៅ ហើយនៅពេលដែលយើងបានឈប់ ប៊ីលីនិងខ្ញុំ ព្រះអម្ចាស់យេស៊ូវមានព្រះបន្ទូលថា "ត្រលប់មកវិញឥឡូវនេះ ហើយចាប់ផ្តើមចូលទៅក្នុងការផ្សាយដំណឹងល្អដូចដែលអ្នកបានធ្វើ។"

ហេតុនេះហើយបានជាខ្ញុំមកទីនេះយប់នេះ ពីព្រោះត្រឡប់មកវិញម្តងទៀតអធិស្ឋានឲ្យអ្នកជំងឺ។ វាមានរឿងវែងឆ្ងាយពីវា ហើយខ្ញុំប្រាកដថាអ្នកនិយមស្តាប់ថេបនៅទីនេះ ដែលឮខ្សែអាត់របស់យើង បានដឹងអំពីរឿងនេះហើយ។ ខ្ញុំមកនេះដើម្បីអធិស្ឋានសម្រាប់អ្នកជំងឺម្តងទៀត។ មានអំណោយទានដ៏អស្ចារ្យជាច្រើននៅក្នុងព្រះ។ ព្រះអាចប្រើវត្ថុទាំងនោះដែលទ្រង់សព្វព្រះហឫទ័យ ប្រសិនបើយើងគ្រាន់តែអនុញ្ញាតឱ្យទ្រង់ធ្វើដូច្នេះ។ ទ្រង់ជាព្រះអម្ចាស់។

ហើយឥឡូវនេះខ្ញុំព្យាយាមមិន...ដាក់ដៃលើមនុស្សទេបើខ្ញុំអាចរក្សាវាបាន ដោយសារតែនៅទីនោះ វាមើលទៅដូចជា (នោះមិនអីទេ) ប៉ុន្តែវាមើលទៅដូចជានរណាម្នាក់នឹងត្រូវបានព្យាបាល ពួកគេនិយាយ "មែនហើយ *អញ្ចេះ-និង-អញ្ចេះ* ដាក់ដៃលើខ្ញុំ។" ឃើញទេ? ខ្ញុំ—ខ្ញុំចូលចិត្តឃើញអ្នកគ្រាន់តែដាក់ដៃលើទ្រង់ លើព្រះគ្រីស្ទ។

គោលបំណងរបស់ខ្ញុំគឺ យើងទាំងអស់គ្នាដឹងដោយបទគម្ពីរថា ការព្យាបាលដ៏ទេវភាពត្រូវបានធានារួចហើយសម្រាប់អ្នកជឿគ្រប់រូប។ វាជាផ្នែក—វាជាផ្នែកមួយនៃការរងទុក្ខរបស់ព្រះយេស៊ូវ៖ "ទ្រង់បានរងរបួសដោយសារអំពើរំលងរបស់យើង ដោយស្នាមជាំរបស់ទ្រង់ យើងបានជាសះស្បើយ។ កាលលោកម៉ូសេលើកពស់លង្ហិនឡើងនៅទីរហោស្ថាន បុត្រមនុស្សក៏ត្រូវលើកឡើងដែរ។" មូលហេតុដូចគ្នា។

ហើយនោះគឺជាប្រភេទតែមួយ ព្រះគ្រីស្ទគឺជាអ្នកតំណាង។ ហើយបន្ទាប់មកប្រសិនបើ—បើដង្វាយធួនចាស់អាចប្រោសឲ្យជាបាន តើដង្វាយថ្មីគួរលើសជាងប៉ុន្មានទៀត ដែលបានទទួលរបស់ល្អជាង បង្កើតការព្យាបាលដ៏ទេវភាព។

ឥឡូវនេះ ព្រះយេស៊ូវត្រូវបានលើកឡើងដោយមូលហេតុដូចគ្នាដែលពស់លង្ហិនធ្វើ (ទ្រង់បានផ្ទុកបាប)៖ ដោយសារសត្វពស់ត្រូវបានធ្វើឡើងពីលង្ហិន ហើយ*លង្ហិន* ជា "និមិត្តសញ្ញានៃការវិនិច្ឆ័យដ៏ទេវភាព" និង*សត្វពស់*បង្ហាញពី "បណ្ដាសារបស់សត្វពស់" ពីសួនច្បារអេដែន ជាកន្លែងដែលអំពើបាប និងជំងឺបានចូល។

ហើយព្រះយេស៊ូវមិនអាច...គ្មាននរណាម្នាក់អាចផ្សាយអំពីព្រះយេស៊ូវគ្រីស្ទជាដង្វាយធួនបាបដោយគ្មានការអធិប្បាយពីការព្យាបាលពីព្រះឡើយ។ គ្មាននរណាម្នាក់អាចផ្សាយដំណឹងល្អដោយគ្មានការអធិប្បាយពីការព្យាបាលដ៏ទេវភាពឡើយ។ ពីព្រោះ ឃើញទេ អ្នកមិន...គាត់មាន...មិនចាំបាច់មានរបស់ជាក់លាក់ទេ។ ដូចជាប្រសិនបើសត្វបានខាំអ្នក អ្នកមិនចាំបាច់កាត់ជើងវាទេ ឬកាត់អីរបស់គាត់—ដៃរបស់គាត់ឬអ្វីក៏ដោយដែលគាត់មាននៅជុំវិញអ្នក។ គ្រាន់តែសម្លាប់គាត់ពីក្បាលគឺជាការស្រេច។

ហើយនោះជារបៀបដែលព្រះយេស៊ូវបានធ្វើនៅពេលទ្រង់—នៅពេលដែលទ្រង់សុគតសម្រាប់អំពើបាប៖ ទ្រង់បានសម្លាប់អ្វីៗទាំងអស់ដែលអំពើបាបធ្លាប់ធ្វើ

ទ្រង់បានលោះយើងទាំងស្រុង។ ឥឡូវនេះយើងកំពុងចូលមក—ទទួលសំណាងដ៏អស្ចារ្យរបស់យើង...សំណាងនៃការរំដោះយើងទាំងស្រុង នៅពេលទ្រង់យាងមកម្តងទៀត។

ដូច្នេះ អ្នកឃើញទេ ជំងឺដោយផ្ទាល់គឺ—គឺបណ្តាលមកពីអំពើបាប។ មាននរណាម្នាក់បានធ្វើបាប។ គ្មានជំងឺទាល់តែមានអំពើបាប។ ហើយពេលដែលអំពើបាបចូលមក នោះជំងឺក៏មកតាមដែរ។ ជំងឺគឺជាគុណលក្ខណៈនៃអំពើបាប។ ហើយបន្ទាប់មក នៅពេលដែលទ្រង់បានសម្លាប់អំពើបាប វាបានយកលក្ខណៈទាំងអស់ទៅជាមួយ។ ឃើញទេ វាត្រូវតែអញ្ចឹង។

ឥឡូវនេះ យើងនឹងអានផ្នែកមួយនៃបទគម្ពីរនៅយប់នេះ។

ខ្ញុំពិតជារីករាយណាស់ដែលបានត្រលប់មកវិញនៅយប់នេះ បងប្អូនប្រុសដ៏ល្អរបស់ខ្ញុំដែលនៅក្នុងការប្រជុំនោះនៅព្រឹកនេះ ហើយរកឃើញបងប្រុស សាកាវាន នៅខាងក្រោយនោះ ផងដែរ និងមិត្តភ័ក្តិរបស់ខ្ញុំជាច្រើននាក់ទៀត។ រីករាយណាស់ដែលមានបងប្អូននៅទីនេះយប់នេះ។ សូមអធិស្ឋានសម្រាប់ខ្ញុំឥឡូវនេះ ប្រសិនបើអ្នកអាច។

ឥឡូវនេះ ចូរយើងបើកទៅក្នុងបទគម្ពីរ សម្រាប់តែអត្ថបទខ្លីប៉ុណ្ណោះ បើព្រះអម្ចាស់សព្វព្រះទ័យ។

2 ហើយចាំថា យប់ថ្ងៃស្អែក អធិស្ឋានសម្រាប់អ្នកឈឺម្តងទៀត។ ហើយឥឡូវនេះនៅពេលដែលខ្ញុំកំពុងអធិប្បាយ...សូមស្តាប់ទាំងអស់គ្នា ព្យាយាមធ្វើបែបនេះ កុំរង់ចាំរឿងណាមួយកើតឡើង។ អ្វីដែលអ្នកត្រូវធ្វើ គឺជឿព្រះឥឡូវនេះ។ ជឿទ្រង់ឥឡូវនេះ! ឃើញទេ?

3 ឥឡូវនេះមានព័ន្ធកិច្ចគ្រប់ប្រភេទ។ ព្រះជាម្ចាស់ នៅក្នុងថ្ងៃចុងក្រោយនេះ ខ្ញុំជឿថា ទ្រង់បានប្រទានឱ្យយើងនូវអ្វីគ្រប់យ៉ាងដែលទ្រង់មាននៅក្នុងសៀវភៅរបស់ទ្រង់។ អ្វីគ្រប់យ៉ាងដែលទ្រង់បានសន្យា យើងបានឃើញ ហើយនៅតែហាក់ដូចជាមនុស្សមិនអាចយល់បាន។ អស់អ្នកដែលតែងតាំង ឱ្យចាប់វាបាន នោះទើបចាប់បាន។ វាធ្វើឱ្យមួយខ្វាក់ ហើយបើកភ្នែករបស់អ្នកផ្សេង។

4 ចូរចាំថា យើងជឿថាព្រះយេស៊ូវគ្រីស្ទគឺនៅដដែលដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ ទ្រង់មិនស្លាប់ទេ ប៉ុន្តែមានជីវិតជារៀងរហូត។ ហើយ

ទ្រង់នៅទីនេះយប់នេះ។ យើងនៅក្នុងវត្តមានរបស់ទ្រង់នៅយប់នេះ ហើយទ្រង់នៅទីនេះ ដើម្បីបញ្ជាក់និងធ្វើឱ្យសេចក្ដីសន្យាណាមួយដែលទ្រង់បានសន្យាសម្រាប់ថ្ងៃនេះ។ ហើយទ្រង់គឺនៅដដែលដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ ដូច្នេះ អ្វីក៏ដោយដែលទ្រង់ធ្លាប់មាន គឺជាទ្រង់ដដែល នៅយប់នេះ។ ដូច្នេះ សូមឲ្យយើងជឿលើទ្រង់ឥឡូវនេះ ពេលយើងអានព្រះបន្ទូលរបស់ទ្រង់ ហើយនិយាយអំពីទ្រង់ក្នុងដប់ប្រាំ ឬម្ភៃនាទីបន្ទាប់។

5 លោកុប្បត្តិ ជំពូកទី២២ និងខទី៧និងទី៨ សម្រាប់ជាវិធីនៃការទទួលបានអត្ថបទមួយ។

*អ៊ីសាកនិយាយនឹងឪពុកថា លោកឪពុកអើយៈ គាត់ក៏ឆ្លើយថា អីកូន។ រួចវានិយាយថា នេះមានភ្លើង និងឧសហើយ តែកូនចៀមសំរាប់ដង្វាយដុតតើនៅឯណា?*

*អ័ប្រាហាំឆ្លើយថា កូនអើយ កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ ដូច្នេះ ក៏នាំគ្នាទៅទៀត។*

6 ព្រ ះអម្ចាស់យេស៊ូវ សូមប្រទានពរដល់ព្រ ះបន្ទូលរបស់ទ្រង់ សូមកុំឲ្យវាត្រឡប់មកវិញជាមោឃៈ ប៉ុន្តែ សូមឲ្យគ្រាប់ពូជធ្លាក់មកលើដី ដែលនឹងនាំមកនូវសេចក្ដីសង្គ្រោះដល់អ្នកដែលខ្វះខាត ទាំងផ្លូវកាយ និងខាងវិញ្ញាណ។ យើងប្ដេជ្ញាខ្លួនយើងចំពោះទ្រង់ ក្រុមជំនុំ ទស្សនិកជន ព្រះបន្ទូល អត្ថបទ បរិបទ។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធគ្រប់គ្រងលើយើង ដែលយើងអាចឃើញព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

7 ខ្ញុំចង់អធិប្បាយតែប៉ុន្មាននាទីឥឡូវនេះនៅលើៈ *ព្រះបានប្រទានផ្លូវសម្រាប់ថ្ងៃនេះ។*

8 ព្រះតែងតែមានផ្លូវ។ មានផ្លូវពីរនោះជា ផ្លូវរបស់យើង ឬផ្លូវរបស់ទ្រង់។ ព្រះមានផ្លូវសម្រាប់ថ្ងៃនេះ ដ្បិតទ្រង់តែងតែបង្កើតផ្លូវសម្រាប់គ្រប់យ៉ាង។ ព្រះជាម្ចាស់ទ្រង់ជ្រាបពីទីបញ្ចប់ ដូច្នេះទ្រង់បានដាក់បទគម្ពីររបស់ទ្រង់សម្រាប់សម័យនីមួយៗ។ ហើយសម័យនោះនៅពេលដែលវាមកដល់...ឥឡូវនេះកុំខកខានក្នុងការមើលរឿងនេះ។ សម័យនោះឯង កាលបើមក តាមធម្មតាព័ន្ធកិច្ចក៏លាយឡំ

ក្នុងសាសនា ជាដើម និងប្រពៃណី រហូតដល់វាមានចម្ងាយមួយលានម៉ាយពីព្រះបន្ទូល។

9 ហើយបន្ទាប់មកព្រះតែងតែបញ្ជូននរណាម្នាក់មកកន្លែងកើតហេតុ ដែលជាហោរា។ ហើយហោរានេះ...ព្រះមិនដែលផ្លាស់ប្តូរប្រព័ន្ធរបស់ទ្រង់ទេ។ ទ្រង់មិនដែលផ្លាស់ប្តូរផ្លូវរបស់ទ្រង់ឡើយ។ ទ្រង់តែងតែធ្វើវាតាមរបៀបដដែល។ ទ្រង់តែងតែមាន ទ្រង់ត្រូវតែធ្វើវានៅពេលនេះ។ ហើយតាមរយៈនេះ ព្រះជាម្ចាស់ធ្វើការ និងបញ្ជាក់ព្រះបន្ទូលនោះ។ ដូចដែលខ្ញុំបាននិយាយទៅកាន់អ្នកកាលពីយប់មិញ ព្រះកំពុងធ្វើការបកស្រាយរបស់ទ្រង់។ ព្រះមិនត្រូវការនរណាម្នាក់បកស្រាយព្រះបន្ទូលទៅកាន់ទ្រង់ឡើយ។ ទ្រង់បកស្រាយវាដោយខ្លួនឯង ដោយបញ្ជាក់វាធ្វើឱ្យវាពិត។ ហើយនៅពេលដែលព្រះមានបន្ទូលថា ទ្រង់នឹងធ្វើអ្វីមួយ នោះទ្រង់ធ្វើ វាមិនមានសំណួរអ្វីទៀតទេ។ នោះជារបៀបដែលទ្រង់ធ្វើ។

10 ដូច្នេះ ព្រះបានបង្កើតផ្លូវសម្រាប់យើង។ ព្រះស្រឡាញ់កូនរបស់ទ្រង់។ ទ្រង់ស្រឡាញ់រាស្ត្រទ្រង់។ ទ្រង់ចង់ជួយពួកគេ។ ទ្រង់ចង់ជួយអ្នកច្រើនជាងអ្នកចង់បានជំនួយ។ ប្រសិនបើអ្នកគ្រាន់តែអាចទទួលបានវានៅក្នុងចិត្តរបស់អ្នក នោះព្រះជាម្ចាស់មានឆន្ទៈជួយអ្នកច្រើនជាងអ្នកដើម្បីជួយខ្លួនឯង។ ប៉ុន្តែទ្រង់មានផ្លូវមួយ ហើយនោះជាផ្លូវតែមួយគត់ដែលទ្រង់នឹងធ្វើគឺតាមផ្លូវទ្រង់។ អ្នកត្រូវតែមកតាមលក្ខខណ្ឌរបស់ទ្រង់ មិនមែនលក្ខខណ្ឌរបស់អ្នកទេ។ លក្ខខណ្ឌរបស់ទ្រង់! អ្នកចង់បានផ្លូវជាក់លាក់មួយ ប៉ុន្តែទ្រង់—ទ្រង់ប្រទានវាដល់អ្នកនូវផ្លូវរបស់ទ្រង់។

11 ដូចណាម៉ាន់កំពុងមុជទឹក—នេះ—ទឹកនៃទន្លេយ័រដាន់។ ហេតុអ្វីបានជាគាត់បាននិយាយថា ទឹកឡើងនៅក្នុងប្រទេសរបស់គាត់ស្អាតជាង និងល្អជាង ប៉ុន្តែនោះមិនមែនជាអ្វីដែលហោរាបាននិយាយនោះទេ។ "មុជនៅទីនេះ។" គាត់មុជម្តង រោគឃ្លង់នៅតែមាន។ ប្រាំមួយដងវានៅតែមាន។ គាត់ត្រូវតែស្តាប់បង្គាប់ ហើយដើរតាមផ្លូវរបស់ព្រះ។ ហើយពេលគាត់បានស្តាប់តាមផ្លូវរបស់ព្រះយ៉ាងពេញលេញ នោះរោគឃ្លង់ក៏ចាកចេញទៅ។

12 ហើយខ្ញុំនិយាយនៅយប់នេះថា បើយើងធ្វើតាមវិធីរបស់ព្រះ នោះជំងឺឃ្លង់នឹងចាកចេញទៅ ជំងឺនឹងចាកចេញ អ្វីៗនឹងចាកចេញ ប៉ុន្តែយើងត្រូវមកផ្លូវទ្រង់សម្រាប់ថ្ងៃនេះ។ ឥឡូវនេះ ការជ្រមុជទឹកនៅក្នុងទន្លេយ័រដាន់នឹងមិនបានការ

ទេឥឡូវនេះ។ នោះគឺសម្រាប់សម័យណាម៉ាន់។ ច្បាប់គឺសម្រាប់—សម្រាប់ជនជាតិយូដា។ ព្រះគុណគឺដោយព្រះគ្រីស្ទ។

13 ប៉ុន្តែសម័យនីមួយៗមានផ្នែកនៃដំណឹងល្អរបស់ខ្លួនដែលបានព្យាករ រួចហើយ។ ព្រះគម្ពីរនេះគឺជាការបើកសម្ដែងពេញលេញរបស់ព្រះយេស៊ូវគ្រីស្ទ។ មិនអាចបន្ថែមទៅវាទៀតទេ ឬអ្វីដែលបានយកចេញពីវាដែរ បើអ្នកធ្វើវានោះអ្នកត្រូវបណ្ដាសា។ យើងមិនអាចបន្ថែមអ្វីទៅក្នុងវាបានទេ ក៏មិនយកអ្វីចេញពីវាបានដែរ។ យើងត្រូវតែមើលនៅទីនេះ ហើយមើលអ្វីដែលបានសន្យាសម្រាប់សម័យនេះ ហើយបន្ទាប់មកឃើញវាកើតឡើង។ នោះគឺជាព្រះដែលបកស្រាយព្រះបន្ទូលរបស់ទ្រង់។ នៅពេលដែលវាបាននិយាយថា "ព្រហ្មចារីនឹងមានគភ៌" នាងមានគភ៌មែន។ នោះគឺជាការបកស្រាយរបស់ព្រះអំពីវា។ អ្វីដែលទ្រង់សន្យា គឺទ្រង់ធ្វើ។

14 ឥឡូវនេះ យើងឃើញថា ព្រះមិនបានផ្លាស់ប្ដូរប្រព័ន្ធរបស់ទ្រង់ក្នុងការធ្វើអ្វីនោះទេ។ ទ្រង់តែងតែធ្វើវាដូចគ្នា។ យើងកំពុងផ្លាស់ប្ដូរឥតឈប់ឈរ ព្រោះថាយើងមានកំណត់។ យើងធ្វើខុសគ្រប់បែបយ៉ាង ហើយអាចកែលម្អ និងកាន់តែប្រសើរឡើង។ ប៉ុន្តែព្រះគឺគ្មានទីបញ្ចប់។ ការសម្រេចចិត្តដំបូងរបស់ទ្រង់គឺល្អឥតខ្ចោះគ្រប់ពេលវេលា។ ទ្រង់មិនអាចឆ្លាតជាងនេះទេ។ ទ្រង់គឺជា...ទ្រង់គឺជាប្រភពនៃប្រាជ្ញាទាំងអស់។ ទ្រង់គឺជាប្រាជ្ញាទាំងអស់។ ទ្រង់មានគ្រប់អំណាច គ្រប់ព្រះចេស្ដា គ្រប់ទីកន្លែង ដឹងសព្វគ្រប់ ហើយគ្មានដែនកំណត់។ ដូច្នេះ ពេលទ្រង់មានបន្ទូលអ្វីមួយ ចូរព្យួរព្រលឹងអ្នកទៅលើវា ពីព្រោះវាជាការពិត។

15 ឥឡូវនេះ ព្រះវិហារខ្លះនិយាយថា "ហើយយើងមិនជឿ*មួយនេះ*ទេ ហើយយើងជឿ*មួយនោះ*។" ព្រះនឹងមិនជំនុំជំរះទោស—ពិភពលោកដោយព្រះវិហារណាមួយឡើយ។ ទ្រង់ជំនុំជំរះវាដោយព្រះយេស៊ូវគ្រីស្ទ ហើយព្រះយេស៊ូវគឺជាព្រះបន្ទូល។ ទ្រង់នឹងជំនុំជំរះក្រុមជំនុំដោយព្រះបន្ទូល។

16 ហើយប្រសិនបើ*នេះ*គឺជាការបើកសម្ដែងរបស់ព្រះយេស៊ូវគ្រីស្ទសម្រាប់គ្រប់សម័យកាល ហើយសម្រាប់សម័យនេះ ទ្រង់បានបើកសម្ដែងនៅក្នុងព្រះគម្ពីរនេះ នូវអ្វីដែលទ្រង់នឹងធ្វើនៅសម័យនេះ ហើយនៅពេលដែលយើងឃើញវាធ្វើវា នៅពេលដែលយើងឃើញទ្រង់ធ្វើអ្វីដែលទ្រង់បានសន្យានឹងធ្វើ។ មិនមែនជាកំណើតព្រហ្មចារី នោះគឺពីរពាន់ឆ្នាំមុន។ ប៉ុន្តែអ្វីដែលទ្រង់បានសន្យានឹងធ្វើនៅ

ថ្ងៃនេះ អ្វីដែលទ្រង់មានបន្ទូលថាទ្រង់នឹងធ្វើនៅថ្ងៃនេះ នោះជាអ្វីដែលទ្រង់មាននៅថ្ងៃនេះ។

17 ជាច្រើនលើកច្រើនសារ មនុស្សនិយាយថា "អញ្ចឹង ខ្ញុំមិនជឿ*វា*ទេ។" មែនហើយ អ្នកបានទទួលអ្នកបកប្រែរបស់អេវ៉ាម្តងទៀត គ្រាន់តែយកផ្នែកខ្លះរបស់វា ប៉ុន្តែមិនមែនទាំងអស់របស់វាទេ។

18 ដូច្នេះ យើងចង់ចាំថា ព្រះនៅតែដដែល។ ព្រះបន្ទូលរបស់ទ្រង់ និងអ្វីដែលទ្រង់មានបន្ទូល ទ្រង់នឹងធ្វើវា។

19 បង្ហាញថាទ្រង់មិនផ្លាស់ប្តូរទេ។ នៅក្នុងលោកុប្បត្តិ១ ទ្រង់មានបន្ទូលថា "សូមឲ្យគ្រប់ពូជចេញមកតាមប្រភេទផលផ្លែរបស់វា។ សូមឲ្យគ្រប់ពូជចេញមកតាមប្រភេទរបស់វា។" ហើយនៅទីនោះ យើងបានប៉ះអ្វីមួយនៅទីនោះ ដែលធ្វើឲ្យអ្នកវិវត្តន៍ទាំងអស់ចេញ។ អ្នកមិនអាចបង្កាត់ពូជរបស់ទាំងនោះបានទេ។ អ្នកយកដូចសេះនិង—និង...និង—សត្វលា បង្កាត់ពួកវាជាមួយគ្នា អ្នកទទួលបានសត្វលាកាត់ ប៉ុន្តែសត្វលាកាត់មួយក្បាលមិនអាចបង្កាត់ពូជមកជាសត្វលាមួយទៀតនោះទេ។ វាឈប់នៅទីនោះ។ "ពូជនីមួយៗនៃប្រភេទរបស់វា។" ពួកវាអាចបង្កាត់ពូជបាន ប៉ុន្តែវាផ្លាស់ប្តូរខ្លួនវាម្តងទៀត បង្ហាញថាវាមិនមានការវិវត្តន៍ដូចនោះទេ។ អត់ ទេបាទ។ វាឈប់នៅទីនោះ។ អ្នកអាចបង្កាត់ស្ពៃស្ពីណាច និងអ្វីផ្សេងទៀតបញ្ចូលរួមគ្នា ហើយវាចេញជាខាត់ណា ប៉ុន្តែអ្នកមិនអាចបង្កាត់ខាត់ណានោះទៅទៀតទេ។ អត់ទេ បាទ។ អ្នកអាចបង្កាត់ពូជពោតកូនកាត់ ប៉ុន្តែអ្នកដាំពោតកូនកាត់នោះម្តងទៀត អ្នកមិនបានអ្វីសោះ។ អ្នកត្រូវបង្កាត់វាឡើងវិញរាល់ពេល។ ដោយសារតែព្រះជាម្ចាស់ទ្រង់មានបន្ទូលថា "សូមឲ្យគ្រប់ពូជចេញផលផ្លែតាមពូជរបស់វា។"

20 ហើយឥឡូវនេះ តាមរយៈការបង្កាត់ពូជ សូមមើលអ្វីដែលពិភពលោកទទួលបានសព្វថ្ងៃនេះ។ ខ្ញុំបានអានអត្ថបទមួយនៅទីនេះ ចេញពី*ទស្សនាវដ្តី ឌីហ្គេស* កន្លែងដែលថា "ម្ភៃឆ្នាំចាប់ពីពេលនេះទៅ ស្ត្រីនឹងមិនមានកូនទេ ប្រសិនបើនៅតែបន្ត។ ពួកគេបរិភោគអាហារបង្កាត់ចម្រុះ។" រឿងរបស់វាគឺ ពួកគេបានបង្កាត់វា ហើយនោះមិនមែនជាវិធីដែលមនុស្សត្រូវបានបង្កើតឡើង ដើម្បីបរិភោគអាហារប្រភេទនោះទេ។ វាត្រូវបានបង្កើតឡើងដើម្បីជួបវានៅក្នុង...ឬញុំាវាតាមរបៀបដែលវាត្រូវបានបង្កើតឡើង។ នោះហើយជាមូលហេតុដែលសព្វថ្ងៃនេះ ដែល

ពួកគេមិនអាចរក្សាសាច់បានហើយអ្វីគ្រប់យ៉ាងគឺដូចដែលវាមាន គឺដោយសារតែវាជាកូនកាត់ ដំណាំក្តៅ ហើយ អូ គ្រប់មធ្យោបាយ។ វាគ្រាន់តែលាយបញ្ចូលគ្នាទាំងអស់។ វាទៅដល់កន្លែងដែលពូជមនុស្សទាំងមូលត្រូវបានបំផ្លាញដោយសមិទ្ធិផលរបស់ពួកគេ ដោយព្យាយាមយកអ្វីដែលព្រះបានធ្វើយ៉ាងល្អ ហើយបង្វែរវាមកវិញ ហើយធ្វើវាតាមវិធីផ្សេង តាមផ្លូវរបស់គេ។ ទុកវាតាមរបៀបដែលព្រះបានបង្កើត!

21 វាថែមទាំងបានទៅដល់កន្លែងដែលពួកគេកំពុងព្យាយាមបង្កាត់ក្រុមជំនុំសព្វថ្ងៃនេះ ពីពិធីបុណ្យជ្រមុជទឹកពិតប្រាកដនៃព្រះវិញ្ញាណបរិសុទ្ធ រហូតដល់ការចាប់ដៃ។ ប្រភេទនៃការប្រោះទឹកខ្លះ ដើម្បីពិធីបុណ្យជ្រមុជទឹក។ អូ ខ្ញុំអើយ! រឿងទាំងមូលគឺជាកូនកាត់។ យើងចង់ត្រលប់មកវិញ។

22 រុក្ខជាតិកូនកាត់ អ្នកត្រូវយកកូនវាទៅបាញ់ថ្នាំ ហើយការពារពីសត្វល្អិតនិងដង្កូវពីវា។ ប៉ុន្តែមិនមែនជារុក្ខជាតិដែលមានសុខភាពល្អពិតប្រាកដ គាត់រឹងមាំល្អ គ្មានសត្វល្អិតមកលើគាត់ទេ។ គាត់មានគ្រប់គ្រាន់ក្នុងខ្លួនគាត់ ដើម្បីកម្ចាត់មេរោគ។

23 ហើយក៏ជាគ្រីស្ទានពិតដែរ! អ្នកមិនចាំបាច់ចិញ្ចឹមហើយគោះគាត់ ហើយប្រាប់គាត់ពី*រឿងនេះ* ឬ*រឿងនោះ*និង*ផ្សេងទៀត*ឡើយ។ គាត់បានទទួលអ្វីមួយនៅក្នុងគាត់ ពិធីបុណ្យជ្រមុជនៃព្រះវិញ្ញាណបរិសុទ្ធ ដែលបោះចោលអ្វីៗដែលនៅសល់។ មិនបាច់អង្វរគាត់ទេ ព្រោះគាត់ជារុក្ខជាតិពិតរបស់ព្រះជាម្ចាស់។ គាត់បានទទួលអ្វីមួយនៅក្នុងគាត់ដែលធ្វើសង្គ្រាម។ គ្រិស្ទានម្នាក់តស៊ូគ្រប់សមរភូមិដើម្បីគាត់អាចឈរបាន។ គាត់ត្រូវតែធ្វើវា ប្រសិនបើគាត់រំពឹងថានឹងមាន។ ហើយតាមរយៈការធ្វើវា វាមានអ្វីមួយនៅក្នុងគាត់ដែលថែរក្សាគាត់។

24 អេវ៉ាបានព្យាយាមបង្កាត់ព្រះបន្ទូល នៅដើមដំបូង។ ព្រះបានប្រាប់នាងថា "ថ្ងៃដែលអ្នកបរិភោគវា ថ្ងៃនោះអ្នកស្លាប់។" នាងព្យាយាមបង្កាត់វាដោយចំណេះដឹងដែលសាតាំងផ្តល់ឱ្យនាង។ ហើយនៅពេលដែលនាងធ្វើ នាងបានបាត់បង់ពូជមនុស្សទាំងមូល នៅទីនោះទៅអារក្ខ នៅពេលដែលនាងព្យាយាមលាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមួយនឹងចំណេះដឹង។

25 វាមិនបានមកពីចំណេះដឹងនៃព្រះបន្ទូលនោះទេ វាមកដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ! "មិនមែនដោយអំណាចដោយកម្លាំងទេ ប៉ុន្តែដោយ

ព្រះវិញ្ញាណរបស់ខ្ញុំ″ ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ។ នោះហើយជារបៀបដែលព្រះធ្វើវា។ ព្រះបន្ទូលរបស់ព្រះគឺជាគ្រាប់ពូជនៃជីវិតអស់កល្បជានិច្ច។

26 ប្រសិនបើអ្នកព្យាយាមបង្កាត់វា តើអ្នកនឹងធ្វើអ្វី? អ្នកនឹងសម្លាប់ខ្លួនឯងជាមួយវា។ វានឹងមិនដំណើរការទេ។ វានឹងមិនលាយលើសពីប្រេងឬទឹកដែលមិនលាយនោះទេ។ វានឹងមិនធ្វើវាទេ។

27 ពួកគេមិនដែលព្យាយាមស្វែងរកអ្វីដែលប្រសើរជាងវិធីរបស់ព្រះក្នុងការធ្វើវានោះទេ។ អ្នកដឹងទេ ពួកគេមិនដែលរកឃើញវិធីណាមួយឃើញ សូម្បីតែ ឱ្យមានមាន់មួយកើតមកលើលោកនេះ ក្រៅពីញាស់ចេញពីស៊ុតរបស់គាត់។ តើអ្នកដឹងទេ? ពួកគេមិនបានរកឃើញវិធីប្រសើរជាងនេះទេ។ មិត្តតូចនោះកើតមកមានស្នាមនៅខាងចុង—នៅចុងបញ្ចប់នៃក្រចករបស់គាត់។ ហើយក្រចករដ៏តូចនោះគាត់បានយកទៅធ្វើការ ហើយទៅអេះ អេះទៅវិញទៅមក រហូតដល់ក្បាលគាត់ចាប់ផ្តើម ធូស្រាល ជ្រើសរើសផ្លូវរបស់គាត់ដោយសេរី។ វាជាផ្លូវដែលព្រះបានប្រទាន។ អ្នកដកគាត់ចេញពីសំបក វានឹងសម្លាប់គាត់។ គាត់នឹងមិនរស់ទេ ប្រសិនបើអ្នកដកគាត់ចេញពីសំបក។ គាត់ត្រូវតែមកតាមផ្លូវរបស់ព្រះ។

28 នោះជាអ្វីដែលជាបញ្ហាជាមួយគ្រីស្ទានសព្វថ្ងៃនេះ។ យើងបានត្រាំពួកគេយ៉ាងទន់ ហើយយើងចាប់ដៃពួកគេ ហើយនាំពួកគេចូលដោយសម្ងាត់ ហើយចូលរួមជាមួយពួកគេក្នុងព្រះវិហារ។ អ្វីដែលពួកគេត្រូវការគឺអាសនៈអធិស្ឋានសម័យបុរាណដែលពួកគេអធិស្ឋាន រហូតដល់ប្រើខ្លួនឯង ចូរមកតាមរបៀបដែលព្រះបានប្រទានមក រហូតដល់ពួកគេបានរំដោះខ្លួនចេញពីពិភពលោក។ បញ្ហារបស់វា ថ្ងៃនេះ ពួកគេបានដាក់ឈ្មោះរបស់ពួកគេនៅលើសៀវភៅ ហើយចូលរួមព្រះវិហារ ហើយនោះជាអ្វីទាំងអស់។ ប៉ុន្តែ ផ្លូវរបស់ព្រះ ដែលជាផ្លូវដែលបានផ្តល់គឺត្រូវស្នាក់នៅទីនោះ ហើយធ្វើផ្លូវរបស់អ្នក រហូតដល់ព្រះប្រទានកំណើតថ្មីដល់អ្នក។ នោះពិតជាត្រឹមត្រូវណាស់។ យកគាត់ចេញ វានឹងសម្លាប់គាត់។

29 នោះហើយជាអ្វីដែលជាបញ្ហា នៅថ្ងៃនេះ ជាមួយប្រជាជន។ កំណើតថ្មីពួកគេទាំងអស់គ្នាគេចពីវា។ ពួកគេមិនចូលចិត្តវាទេ។ អូ ពួកគេបានជំនួសអ្វីមួយសម្រាប់កំណើតថ្មី "ក្រោកឡើងហើយជឿ ហើយនោះជាអ្វីដែលអ្នកត្រូវធ្វើ។″ អារក្សក៏ជឿ ខ្លួនឯងដែរ ហើយអ្នកដឹងថាវាមិនបានកើតជាថ្មីទេ។ មានកំណើតថ្មី។

មានអ្វីមួយទៅជាមួយវា ជាប្រភេទមិនសម គ្មានរស់ជាតិ គ្មានឪជារស់សម្រាប់ពិភពលោក។

30 កំណើតណាមួយគឺជាបញ្ហា។ ខ្ញុំមិនខ្វល់ថាវានៅឯណាទេ។ ប្រសិនបើវាស្ថិតនៅក្នុងបិចជ្រូក ឬ—ឬមន្ទីរពេទ្យ។ កំណើតគឺជារឿងរញ៉េរញ៉ៃ។

31 កំណើតថ្មីក៏ដូច្នោះដែរ! វានឹងធ្វើឱ្យអ្នកធ្វើអ្វីដែលអ្នកមិនបានគិតថាអ្នកនឹងធ្វើ។ វានឹងធ្វើឱ្យអ្នកចុះទៅអាសនៈ ហើយយំ ស្រែក លាងមុខរបស់អ្នកដែលបានតុបតែង លើកដៃសរសើរតម្កើងព្រះជាម្ចាស់ និយាយភាសាដទៃ និងអ្វីៗគ្រប់យ៉ាង។ កំណើតថ្មីនឹងធ្វើដូច្នេះ ព្រោះវាជាវិធីដែលព្រះបានប្រទានឲ្យកើតម្តងទៀត។

32 អ្នកត្រូវតែស្លាប់។ អ្នកត្រូវតែស្លាប់មុនពេលអ្នកអាចកើតជាថ្មី។ គ្រាប់ពូជណាមួយត្រូវស្លាប់ មុនពេលវាបង្កើតឡើងវិញម្តងទៀត។ ទាល់តែវាងាប់ វានៅម្នាក់ឯង។ បុរសម្នាក់ត្រូវស្លាប់ចំពោះការគិតរបស់គាត់។ គាត់ត្រូវតែស្លាប់ចំពោះការគិតពីអ្វីក្រៅពីព្រះបន្ទូលរបស់ព្រះ ហើយមកតាមផ្លូវរបស់ទ្រង់។ នោះជាដីរបស់ព្រះ។ យើងមិនជួបទ្រង់តាមគំនិតរបស់យើងទេ។ យើងជួបទ្រង់តាមអ្វីដែលទ្រង់មានបន្ទូលថានឹងធ្វើ។ នោះជាផ្លូវដែលព្រះបានប្រទានសម្រាប់វា។ មនុស្សគេចវាពួកគេមិនចង់បានវា។ ប៉ុន្តែវាជាការពិត ដូចគ្នា។ វានឹង បង្កើតសេចក្តីស្លាប់ ហើយអ្នកត្រូវតែស្លាប់ ស្លាប់តាមការគិតរបស់អ្នក។

33 "មែនហើយ ខ្ញុំដឹងថាគម្ពីរចែងថាវា ប៉ុន្តែខ្ញុំមិនអាចយល់បានទេ។" បន្ទាប់មកស្នាក់នៅទីនោះរហូតដល់ព្រះបើកសម្តែង។ ត្រឹមត្រូវហើយ។ វាមាន...នោះជាកំណើតថ្មី។

34 ទានិងសត្វក្ងាន ពួកគេមិនដែលរកផ្លូវល្អសម្រាប់ពួកវាទៅភាគខាងត្បូងទេ ជាជាងការហែលជាមុន។ ហើយនោះជាការត្រឹមត្រូវ។ អ្នកនឹងឃើញពួកគេទាំងអស់ ហើយពួកគេនឹងមកដោយខ្លួនឯង សភាវគតិមួយចំនួនបានទាក់ទាញពួកគេឱ្យចូលគ្នា ហើយពួកគេបានរួបរួមគ្នា និងហែលមុនពេលពួកគេហោះហើរមុនពេលពួកគេទៅភាគខាងត្បូង។ តើវាគឺជាអ្វី? វាជាពេលវេលារស់ឡើងវិញនៅពេលដែលពួកគេទាំងអស់គ្នាជួបជុំគ្នា។ តើអ្នកធ្លាប់ឮការនិយាយលេងសើចបែបនេះក្នុងជីវិតរបស់អ្នកដែរឬទេ ថាពេលឮសត្វក្ងានជុំគ្នា ឬជាសត្វទា? ខ្ញុំ

មិនដែលឮបែបនេះទេ! ហើយពួកគេមាន...គ្មានវិធីណា ល្អជាងសម្រាប់ពួកគេធ្វើវាទេ។

35 ជាច្រើនដង ឡើងលើព្រៃភាគខាងជើង ខ្ញុំមើលការចាប់ផ្ដើមដំបូងនៃអាកាសធាតុត្រជាក់ នៅប្រទេសកាណាដា។ កូនទាមួយហ្វូងកើតនៅទីនោះ នៅលើបឹងនោះ ពួកគេមិនដែលចេញពីបឹងនោះទេ កូនតូចនេះមិនមានទេ។ ហើយរឿងដំបូងដែលអ្នកដឹង គឺខ្យល់ត្រជាក់ធ្លាក់មកពីខាងជើង។ សត្វតូចល្អិតសត្វហែលតូចនេះ ទើបតែកើតក្លាយជាអ្នកដឹកនាំ ចេញទៅទីនោះភ្លាមៗ នៅកណ្ដាលស្រះនោះ ទទះស្លាបតូចរបស់គាត់ឡើងលើអាកាស ហក់ឡើងបួនទៅប្រាំដង ហើយកូនទាទាំងអស់នៅលើស្រះបានមករកគាត់។ ហើយគាត់បានក្រោកពីទីនោះ ហើយទៅត្រង់ទៅរដ្ឋ ល្វីសសៀនណាតាមដែលគាត់អាចទៅបាន គឺទៅវាលស្រែ។

36 ហេតុអ្វី? ពួកគេមិនដែលរកវិធីប្រសើរជាងសម្រាប់គេដើម្បីទៅដល់ទីនោះទេ។ អ្នកមិនអាចចិញ្ចឹមពួកវាជាមួយគ្នាបានទេ។ អ្នកដាក់វាក្នុងចង្ក្រានបាយហើយ...ទ្រុងមួយ ហើយដឹកពួកគេទៅទីនោះ។ ប្រវឹកមួយនោះមានអារម្មណ៍ល្អជាង។ ហើយអ្នកដាក់គាត់នៅក្នុងទ្រុងនោះ ដើម្បីយកគាត់ទៅទីនោះ គាត់ដឹងថាគាត់បានទៅកាន់ទីសម្លាប់។ នោះពិតជាត្រឹមត្រូវណាស់។ គាត់ទៅតាមផ្លូវដែលព្រះបានប្រទាន។

37 នោះជាវិធីដែលមនុស្សគួរធ្វើនៅថ្ងៃនេះ មិនត្រូវបានក្រុមនិកាយមួយចំនួនមកចិញ្ចឹមឡើយ។ ប៉ុន្តែ ចូរមកតាមរបៀបដែលព្រះបានមានបន្ទូលមក ដោយការជ្រមុជទឹកនៃព្រះវិញ្ញាណបរិសុទ្ធ និងកំណើតថ្មី ការរស់ឡើងវិញដ៏កក្រើក។ មិនចូលរួមព្រះវិហារ សុំពីផ្ទះមួយទៅផ្ទះមួយ និងហុចទស្សនាវដ្ដី ប៉ុន្តែកំណើតមួយកើតជាថ្មី ពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ជាមាគ៌ារបស់ព្រះ រំដោះខ្លួនចេញពីលោកីយ៍។ ត្រូវហើយ! ជឿព្រះបន្ទូលរបស់ព្រះ! ផលាគឺនៅទីនេះ។ នោះហើយជាអ្វីដែលយើងត្រូវជឿ។

38 បុរស អ្នកមិនអាច...ខ្ញុំមិនខ្វល់ថាមានបុរសប៉ុន្មាននាក់ដែលព្យាយាមទៅស្រះទានៅទីនោះ ហើយនិយាយថា "ឥឡូវនេះ ចាំបន្តិចចុះ កូនទាតូច មានរឿងចង់និយាយជាមួយអ្នក។ យើងមានទាដែលមានការអប់រំនៅទីនេះ។ គាត់មានសញ្ញាបត្របណ្ឌិត និងអិលអិល.ឌី ខ្ញុំប្រាប់អ្នក គាត់អាចដឹកនាំអ្នកបាន។"

39 ទាទាំងនោះមានការយល់ដឹងច្រើនជាងនោះទៅទៀត។ បាទ មែនហើយ។ ពួកគេមិនខ្វល់ពីការអប់រំដ៏ល្អរបស់គាត់ទេ ទោះជាអ្វីក៏ដោយ។ ពួកគេអាចប្រាប់ពីស្មៀតជាក់លាក់ដែលគាត់ផ្តល់។ វាជាសភាវគតិ។ អូ ខ្ញុំអើយ! ក្រុមជំនុំគួរតែដឹងច្រើនអំពីព្រះបន្ទូលរបស់ព្រះ!

40 វាជាសំឡេងមិនប្រាកដប្រជា។ ព្រះគម្ពីរបាននិយាយថា ប៉ុលបាននិយាយថា "បើត្រែបញ្ចេញសំឡេងមិនច្បាស់ តើនរណាអាចត្រៀមខ្លួនសម្រាប់ប្រយុទ្ធបាន?" នោះជាការត្រឹមត្រូវ ប្រសិនបើព្រះវិហារ—ប្រសិនបើព្រះវិហារផ្តល់សំឡេងមិនច្បាស់លាស់ "ចូលរួម។"

41 ព្រះទ្រង់មានបន្ទូលថា "កំណើត!" អ្វីដែលកំណើតបានធ្វើនៅទីនោះ កំណើតក៏ធ្វើដូចសព្វថ្ងៃនេះ ដោយសារព្រះយេស៊ូវគ្រីស្ទគឺនៅដដែលដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ អ្វីដែលទ្រង់ធ្វើកាលនោះ ទ្រង់គង់នៅសព្វថ្ងៃនេះ។ អ្វីដែលពួកគេបានធ្វើនៅពេលនោះ គឺជារឿងដដែលដែលយើងធ្វើនៅថ្ងៃនេះ។ របៀបដែលពួកគេទទួលបាននៅទីនោះ គឺជារឿងដូចគ្នាដែលពួកគេធ្វើសព្វថ្ងៃនេះ។ អ្វីដែលពួកគេទទួលបានដូចគ្នាថ្ងៃនេះ គឺជាអ្វីដែលពួកគេមាននៅទីនោះ។ ប្រសិនបើវាមកទាំងអស់ វាមកតាមនោះ។ នោះជាផ្លូវដែលព្រះបានប្រទាន។ វាមិនដែលផ្លាស់ប្តូរទេ។

42 សត្វទាមិនផ្លាស់ប្តូរទេ។ ពួកគេហែលឆ្លង ជារៀងរាល់ឆ្នាំ ទៅខាងជើងខាងត្បូង ហើយទៅណាក៏ដោយ។ ពួកគេហែលជាមុន។

43 នោះជារបៀបដែលព្រះធ្វើ។ ទ្រង់បញ្ជូនព្រះបន្ទូលរបស់ទ្រង់នៅរដូវកាលរដូវនោះ បន្ទាប់មកវាត្រូវបានបង្ហាញ។ ហើយខ្ញុំមិនខ្វល់ថាមានរឿងប៉ុន្មានទៀតដែលបន្ត នៅពេលដែលពួកគេឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានសន្យាសម្រាប់ថ្ងៃនោះ ត្រូវបានបញ្ជាក់ និងសន្យា គ្មានអ្វីអាចបញ្ឈប់ពួកគេបានឡើយ។ "ព្រហ្មចារីនឹងមានផ្ទៃពោះ។" ហើយនៅពេលដែលពួកគេនិយាយ...

44 "ព្រះអម្ចាស់ ជាព្រះនៃយើង នឹងលើកហោរាមួយរូបមកប្រដូចនឹងខ្ញុំ" លោកម៉ូសេបាននិយាយ។

45 ហើយនៅពេលដែលពួកគេបានឃើញបុរសនេះមកធ្វើអ្វីដែលគាត់បានធ្វើ ពួកគេដឹងថានោះគឺជាព្រះមេស្ស៊ី។ ពេលលោកភីលីពឃើញការនោះ គាត់

និយាយថា "អ្នកគឺជាព្រះគ្រីស្ទ។ ព្រះអង្គជាស្តេចនៃជនជាតិអ៊ីស្រាអែល។" គាត់បានដឹងវាដោយសារតែព្រះបន្ទូលបានសន្យាវា ហើយវាកំពុងរស់នៅក្នុងថ្ងៃនោះ។ មិនថាមានពួកផារីស៊ីប៉ុន្មាននាក់ ពួកសាឌូស៊ី កំពុងឈរនៅជុំវិញប៉ុន្មានទេ បណ្ឌិតនៃទេវភាព វាមិនបញ្ឈប់គាត់បន្តិចឡើយ ដោយសារតែគាត់កំពុងស្វែងរកទីសម្គាល់នោះ។ នៅពេលដែលគាត់បានឃើញវារួចរាល់ នោះគឺជាទីសម្គាល់នៃសម័យកាល។ នោះជាអ្វីដែលពួកគេកំពុងស្វែងរក គឺជាផ្លូវរបស់ព្រះបានផ្តល់ឲ្យ។ បាទ មែនហើយ។

46 ឥឡូវនេះអ្នកមិនអាចផ្តល់ការអប់រំ ឱ្យទាមួយបានទេ។ គាត់មិនអាចទទួលបានទេ។ គាត់នឹងមិនចង់បានវាទេ។ ប្រវឹកដែលនៅសេសសល់នឹងមិនដើរតាមគាត់ទេ ទោះបីជាគាត់អាចនិយាយបានថាគាត់មានកម្រិតណាក៏ដោយ។ "ឥឡូវនេះ មើលនៅទីនេះ ខ្ញុំបានទៅសាលាទា។ ខ្ញុំដឹងទាំងអស់អំពីវា។ ខ្ញុំបានបញ្ចប់ការសិក្សាហើយ។ ខ្ញុំដឹងរឿងទាំងអស់នេះ។" វានឹងមិនធ្វើល្អបន្តិចទេ។ គ្មានសត្វទាផ្សេងទៀតនឹងដើរតាមគាត់ទេ ប្រសិនបើពួកគេជាទាពិតប្រាកដ អាម៉ែន ដោយសារតែពួកគេកំពុងស្វែងរកសញ្ញាជាក់លាក់មួយ។ ពេលឃើញសញ្ញានោះ គេជឿ។

47 ហើយបើទាមានវិធីអាចដឹងបាន តើគ្រិស្ទានកើតជាថ្មីបានដឹងលើសជាងអំបាលម៉ានទៀត? យើងគួរតែស្គាល់ព្រះយេស៊ូវគ្រីស្ទនៅក្នុងអំណាចនៃការរស់ឡើងវិញរបស់ទ្រង់។ ត្រូវហើយ។ ព្រះធ្វើតាមវិធីដែលព្រះបានប្រទាន។

48 សូមចាំថា ការអប់រំនឹងមិនមែនជាឧបករណ៍សម្រាប់នាំពួកគេទៅកាន់កន្លែងដែលព្រះបានប្រទាននោះទេ។ ឧបករណ៍ដែលពួកគេមានគឺសភាវគតិ។ ហើយពួកវាជាសត្វប្រវឹកដឹងថាសភាវគតិនោះនឹងនាំពួកគេទៅកន្លែងដែលព្រះបានប្រទានមក។

49 ព្រះវិញ្ញាណបរិសុទ្ធក៏នាំក្រុមជំនុំទៅកន្លែងដែលព្រះបានប្រទានឲ្យដែរ។ មិនមែនដើម្បីចូលរួមក្រុមជំនុំទេ ប៉ុន្តែត្រូវបំពេញដោយវត្តមានរបស់ទ្រង់ ដើម្បីឃើញព្រះបន្ទូលរបស់ទ្រង់បានបង្ហាញឱ្យឃើញ បានបញ្ជាក់។ នោះជាផ្លូវរបស់ព្រះសម្រាប់ក្រុមជំនុំ តែងតែសម្រាប់ប្រជាជន នាំពួកគេទៅកន្លែងដែលព្រះជាម្ចាស់បានរៀបចំសម្រាប់ពួកគេ។ នោះជាអ្វីដែលព្រះវិហារគួរតែមាននៅថ្ងៃនេះ។ ឥឡូវនេះ យើងដឹងថាវាជាការពិត។

50 មិនមានវិធីល្អជាងសម្រាប់...ពួកគេមិនបានរកឃើញវិធីល្អជាងសម្រាប់ទារកដើម្បីទទួលបាននូវអ្វីដែលវាចង់បាន ជាជាងការយំនោះទេ។ ប្រសិនបើអ្នកដាក់កណ្ដឹងគាត់ ហើយនិយាយថា "ជូនៀ អូនទើបតែអាយុបីថ្ងៃទេ តែឥឡូវបើកូនចង់បាន នៅពេលអ្នកចង់បានដបដោះគោ ចូរលើកកណ្ដឹងនេះឡើង ហើយបន្លឺវាឡើង" មើលថាតើវាដំណើរការឬអត់។ វាមិនដំណើរការទេ។ ទារកយំសម្រាប់អ្វីដែលវាចង់បាន។ នោះជាវិធីដែលព្រះបានប្រទាន។ អ្នកយំកាន់តែខ្លាំង...កុំវាយមិត្តតូចនោះឡើយ គាត់ដើរតាមផ្លូវដែលព្រះបានប្រទានមកប៉ុណ្ណោះ។ គាត់ចង់បានអ្វីមួយ។ ត្រូវហើយ។ វាជាវិធីតែមួយគត់ដែលគាត់ដឹងដើម្បីហៅទៅម្ដាយរបស់គាត់ ស្រែករកវា យំរកវា។ ត្រូវហើយ។

51 ព្រះផ្ដល់អនុសាសន៍នេះសម្រាប់កូនចៅរបស់ទ្រង់។ ព្រះផ្ដល់អនុសាសន៍នេះសម្រាប់កូនចៅដែលមានជំនឿរបស់ទ្រង់។ ទ្រង់បានធ្វើ។ មិនមែនជាការនិយាយដោយបញ្ញា មិនមែនជាទ្រឹស្ដីដ៏អស្ចារ្យមួយចំនួន ទេវវិទ្យាត្រូវបង្រៀន។ ទ្រង់ចង់ឱ្យអ្នកយំសម្រាប់តម្រូវការរបស់អ្នក។ ហើយត្រូវហើយ ស្រែករកវា! អ្នករឹងពេកនិងចចេសពេក អ្នកនឹងមិនទទួលបានវាទេ។ បើអ្នកត្រៀមខ្លួនបន្តិចហើយយំ ព្រះនឹងប្រទានវាមកអ្នក។ ទ្រង់ចូលចិត្តស្ដាប់កូនរបស់ទ្រង់យំ។ យំតាមតម្រូវការរបស់អ្នកចំពោះព្រះ! ព្រះចង់បានវា។ នោះជាវិធីដែលទ្រង់បានប្រទាន។ ស្រែករកវា! នោះហើយជារបៀបដែលទារកយំ នោះជារបៀបដែលទ្រង់ចង់ឱ្យអ្នកយំ។

"យំយូរប៉ុណ្ណា?"

52 តើទារកយំរយៈពេលប៉ុន្មាន? រហូតដល់គាត់ពេញចិត្ត។ ហើយនោះជាវិធីដែលគ្រិស្ទានគួរធ្វើ ជាកូនរបស់ព្រះ។ បើអ្នកឃើញថាព្រះបានធ្វើតាមការសន្យា ចូរកុំបោះបង់ចោល ចូរយំរហូតដល់មានចម្លើយ។ យំរហូតដល់អ្នកឃើញព្រះបញ្ជាក់ព្រះបន្ទូលរបស់ទ្រង់។ នៅពេលដែលព្រះជាម្ចាស់បញ្ជាក់ព្រះបន្ទូលរបស់ទ្រង់ ហើយបញ្ជាក់ថាវានៅទីនេះ នោះអ្នកមិនចាំបាច់យំទៀតទេ អ្នកបានទទួលវា ដើរចេញហើយអរគុណទ្រង់សម្រាប់វា។ ទាល់តែអ្នកធ្វើដូច្នេះ ចូរស្រែករហូតទាល់តែអ្នកទទួលបាន។ ខ្ញុំចូលចិត្តបែបនោះ តស៊ូ ប្រកាន់ខ្ជាប់។

53 មិនមែនជារុក្ខជាតិកូនកាត់ទេ មិនមែនជារុក្ខជាតិដែលត្រូវចិញ្ចឹម កូនតូចហើយខ្ចប់ជុំវិញនោះទេ។ គ្រិស្ទានគឺពិតប្រាកដ ពិតប្រាកដ កើតជាថ្មីមក ជា

អត្ថបទរបស់ព្រះ។ ពួកគេតស៊ូដើម្បីតំណែងរបស់ពួកគេ ហើយប្រយុទ្ធរហូតដល់ពួកគេបានបញ្ចប់នៅលើផែនដីនេះ។ រាល់ចលនារបស់វាគឺជាការប្រយុទ្ធ។

54 ព្រះបានមានបន្ទូលប្រាប់លោកម៉ូសេ ទ្រង់ប្រទានដីដល់គាត់។ គាត់ប្រាប់យ៉ូស្វេថា "គ្រប់កន្លែងដែលខ្ញុំបានឲ្យអ្នករាល់គ្នាជាន់ជើង ឬដាក់បាតជើងលើ នោះគឺខ្ញុំបានផ្ដល់ឱ្យអ្នក។" ពួកគេត្រូវតែតស៊ូដើម្បីបានគ្រប់អ៊ីញរបស់វា។ ដូច្នេះយើងប្រយុទ្ធដើម្បីបានគ្រប់អ៊ីញរបស់វា។ វាមិនមែនជាអ្វីដែលត្រូវចិញ្ចឹមដូចកូនក្មេងនោះទេ ហើយនៅជុំវិញបែបនោះ ហើយនិយាយថា "អញ្ចឹង ខ្ញុំនឹងនាំអ្នកទៅទីនោះ មើលអ្វីដែលអ្នកគិតអំពីវា។ អ្នកឆ្លងកាត់គំនិតរបស់អ្នក។" នោះមិនមែនជាផ្លូវទៅមុខទេ។

55 មកជាមួយការតាំងចិត្ត។ មកនោះអ្នកនឹងស្នាក់នៅទីនោះរហូតដល់វាចប់។ ចូរនៅទីនោះរហូតដល់ព្រះឆ្លើយតប និងបញ្ជាក់។ បុរសម្នាក់ដែលជឿលើព្រះ អាចមើលឃើញវត្តមានរបស់ព្រះ មានអារម្មណ៍ថាមានវត្តមានរបស់ព្រះ ដឹងពីវត្តមានរបស់ព្រះ ហើយដឹងថាទ្រង់នៅទីនេះ។ ទ្រង់នៅទីនេះ ដើម្បីឆ្លើយតបរាល់អ្វីដែលទ្រង់បានសន្យាសម្រាប់ថ្ងៃនេះ។ បន្ទាប់មកយំរហូតដល់អ្នកទទួលបានវា! សង្កត់លើទ្រង់។ កុំចាកចេញ បើត្រូវស្នាក់នៅទាំងយប់ទាំងថ្ងៃកដោយ។ ព្រះមិនចង់ឱ្យកូនរបស់ទ្រង់ស្ដាប់សុន្ទរកថាបញ្ញវន្តនោះទេ។ ទ្រង់ចង់ឱ្យពួកគេស្រែកទៅកាន់វារហូតដល់ការសន្យាត្រូវបានបញ្ជាក់។

56 អ័ប្រាហាំនៅទីនេះត្រូវការយញ្ញបូជា។ តើមានអ្វីកើតឡើង? ព្រះបានផ្ដល់កូនចៀមមួយដល់គាត់។ នោះជាវិធីដែលព្រះបានប្រទាន។ គាត់ត្រូវការយញ្ញបូជា ដូច្នេះព្រះបានប្រទានវា។ ក្រោយមក គាត់បានដាក់ឈ្មោះកន្លែងនោះថា *យេហូវ៉ា-យីរេ*។ "ព្រះអម្ចាស់នឹងផ្គត់ផ្គង់ការបូជាដល់ព្រះអង្គផ្ទាល់។"

57 ឥឡូវនេះ យ៉ូប មានពេលមួយ ហោរាចាស់ យ៉ូប។ គាត់គឺជាហោរា។ គាត់មានបញ្ហា។ សាតាំងចង់ល្បងគាត់ ហើយវាបានធ្វើឲ្យមានបូសរមាស់។ ហើយវាសម្លាប់កូនរបស់គាត់ វាយកភាគហ៊ុនរបស់គាត់ វាបានយកទាំងអស់ដែលគាត់មាន ហើយវាបានបំបែកគាត់ចេញជាបូសដំបៅ។

58 ហើយអ្នកសម្រាលទុក្ខគាត់ មកធ្វើអី? ពួកគេមិនបានផ្ដល់អ្វីក្រៅតែពីការមើលងាយ ចំអកដាក់គាត់ប្រាប់គាត់ថា "ហេតុអ្វីបានជាអ្នកបានធ្វើបាបដោយសម្ងាត់។"

59 ហើយយ៉ូបបានស្មោះត្រង់។ គាត់ស្រែក។ គាត់ប្រាកដថា គាត់កំពុងធ្វើតាមបទបញ្ញត្តិរបស់ព្រះ។ គាត់បានធ្វើតាមអ្វីដែលព្រះបានសន្យានឹងធ្វើ។ អ្វីដែលព្រះបានសន្យានឹងគាត់ថា ទ្រង់នឹងឈរក្បែរគាត់ ក្រោមការថ្វាយយញ្ញបូជា ហើយទ្រង់គង់នៅទីនោះ។

60 ដូច្នេះ ព្រះបានផ្តល់ការនិមិត្តមួយដល់គាត់។ គាត់គឺជាហោរា។ តើគាត់បានឃើញអ្វី? គាត់បានឃើញព្រះបន្ទូល ព្រះយេស៊ូវគ្រីស្ទ។ គាត់បាននិយាយថា "ខ្ញុំដឹងថាព្រះដ៏ប្រោសលោះរបស់ខ្ញុំមានព្រះជន្មរស់។ ហើយនៅថ្ងៃចុងក្រោយទ្រង់នឹងឈរនៅលើផែនដី។ ទោះបីដង្កូវស៊ីស្បែកបំផ្លាញរូបកាយនេះក៏ដោយ ក៏ខ្ញុំនឹងឃើញព្រះក្នុងសាច់ឈាមខ្ញុំដែរ។" ឃើញទេ ទ្រង់បានផ្តល់ការនិមិត្តអំពីការរស់ឡើងវិញសម្រាប់គាត់។ គាត់ជាហោរា គាត់បានឃើញព្រះបន្ទូល។ គាត់បានឃើញព្រះបន្ទូល ហើយគាត់បានដឹងថា ឆ្អឹង និងរូបកាយរបស់គាត់នឹងរស់ឡើងវិញនៅថ្ងៃចុងក្រោយ។ គាត់ត្រូវបានគេសួរថាតើគាត់ដឹងថាព្រះនៅទីណាប្រសិនបើគាត់គ្រាន់តែមើលឃើញ។

61 គាត់បាននិយាយថា "ផ្កាមួយងាប់ វារស់ឡើងម្តងទៀត។ ដើមឈើរលំ វាងើបឡើងម្តងទៀត តែមនុស្សម្នាក់ដេកស្លាប់ បាត់ទៅហើយ តើវានៅឯណា? ឱព្រះអង្គលាក់ទូលបង្គំនៅក្នុងផ្នូរ ហើយរក្សាទូលបង្គំនៅទីស្ងាត់កំបាំងរហូតដល់ព្រះពិរោធរបស់ព្រះអង្គកន្លងផុតទៅ។"

62 ពេលនោះ ផ្គរលាន់ក៏ចាប់ផ្តើមបន្លឺឡើង ផ្លេកបន្ទោរក៏ចាប់ផ្តើមភ្លឺ ព្រះវិញ្ញាណនៃព្រ ះអម្ចាស់យាងមកសណ្ឋិតលើហោរា។ គាត់ក៏ក្រោកឡើង ឃើញការយាងមករបស់ព្រ ះអម្ចាស់ គាត់ក៏ស្រែកឡើងថា "ខ្ញុំដឹងថាព្រះប្រោសលោះរបស់ខ្ញុំមានព្រះជន្មគង់នៅ ហើយនៅថ្ងៃចុងក្រោយ ទ្រង់នឹងឈរនៅលើផែនដី។ ទោះបីដង្កូវស៊ីស្បែកបំផ្លាញរូបកាយនេះក៏ដោយ ខ្ញុំនឹងឃើញព្រះក្នុងសាច់ឈាមខ្ញុំ។" ព្រះទ្រង់បានប្រទានព្រះបន្ទូល គឺព្រះយេស៊ូវគ្រីស្ទ ហើយគាត់បានឃើញទ្រង់ ហើយបានហៅទ្រង់ជាព្រះប្រោសលោះគាត់។

63 អ៊ីស្រាអែលត្រូវការវិធីចេញពីស្រុកអេស៊ីប ហើយព្រះបានប្រទានហោរាម្នាក់ដល់ពួកគេ។ ហោរាម្នាក់ដែលបង្ហាញព្រះបន្ទូលដែលបានសន្យាចំពោះអ័ប្រាហាំ។ ពិតប្រាកដណាស់ ផ្លូវដែលព្រះប្រទាន! ពួកគេមិនអាចហ្វឹកហ្វឺនទាហាន ពួកគេមិនអាចធ្វើ*បែបនេះ*បានទេ ពួកគេមិនអាចធ្វើ*ដូច្នោះ*បានដែរ។ អ្វីដែលពួកគេបាន

ធ្វើគឺរង់ចាំផ្លូវដែលព្រះបានប្រទាន។ ហើយទ្រង់មានបន្ទូលថា "ទ្រង់នឹងនាំមនុស្សទាំងនោះចេញ បន្ទាប់ពីបួនរយឆ្នាំ។ ប្រជាជនរបស់ទ្រង់នឹងស្ថិតក្នុងភាពជាទាសករ ប៉ុន្តែទ្រង់នឹងនាំពួកគេចេញដោយព្រះហស្តដ៏ខ្លាំងខ្លា។ ទ្រង់នឹងបង្ហាញទីសំគាល់ និងការអស្ចារ្យរបស់ទ្រង់ ហើយទទួលបានសិរីរុងរឿងនៅក្នុងប្រជាជាតិនោះ។"

64 ចុះបុរសនេះ នៅពេលគេយំហើយស្រែក! ហើយឥឡូវនេះ ចូរចាំថា ការយំទាំងអស់នឹងមិនបានសង្គ្រោះពួកគេឡើយ រហូតដល់ពេលនោះត្រូវបានសម្រេច។

65 រឿងទាំងនេះដែលយើងកំពុងមើលឃើញសព្វថ្ងៃនេះ មិនអាចកើតឡើងពីម្ភៃឆ្នាំមុន ឬសែសិបឆ្នាំមុនទេ។ ថ្ងៃនេះវាកើតឡើង។ នេះជាម៉ោង! នេះជាពេលវេលា! ឥឡូវនេះគឺជាពេលវេលាដែលវាត្រូវបានបំពេញ។ ហេតុអ្វី? ព្រះបានសន្យាវា ហើយវានៅទីនេះ។

66 ពួកគេបាននិយាយវាមួយរយឆ្នាំមុន ថា "ពិធីបុណ្យជ្រមុជទឹកនៃព្រះវិញ្ញាណបរិសុទ្ធមិនអាចមានម្តងទៀតទេ។" ពួកគេបាននិយាយថា ហាសិបឆ្នាំមុន "ព្រះវិញ្ញាណបរិសុទ្ធ..." ប៉ុន្តែអ្នករាល់គ្នាជាមនុស្សថ្ងៃទី៥០បានបង្ហាញឲ្យឃើញគឺវា ថាវាជាពេលរបស់ព្រះដើម្បីបង្ហូរព្រះវិញ្ញាណបរិសុទ្ធ។ មិនថាមេតូឌីស្ទ បាទីស្ទ ប្រេសប៊ីធើរៀន លូធើរាន បាននិយាយអ្វីនោះទេ អ្នកនៅតែត្រឹមត្រូវជាមួយនឹងព្រះបន្ទូលរបស់ព្រះ។ បុរសក្លាហានបានចេញទៅទីនោះ ហើយបន្តរហូតដល់ពិធីបុណ្យជ្រមុជទឹកនៃព្រះវិញ្ញាណបរិសុទ្ធបានមក ពួកគេនិយាយភាសាដទៃ ហើយលើកតម្កើងព្រះជាម្ចាស់។ គ្មាននរណាម្នាក់អាចប្រាប់អ្នកពីភាពខុសគ្នានោះទេ។ ព្រះជាអ្នកបកប្រែផ្ទាល់របស់ទ្រង់ អ្នកបានទទួលវាហើយ។ អ្នកប្រហែលជាមិនអាចពន្យល់បាន ប៉ុន្តែអ្នកដឹងថាអ្នកបានទទួលវា។ តើអ្នកណាអាចពន្យល់ព្រះបាន? គ្មាននរណាម្នាក់អាចធ្វើបានទេ។

67 ខ្ញុំមិនអាចប្រាប់អ្នកពីរបៀបដែលព្រះអាចបង្ហាញការនិមិត្តនោះទេ ប៉ុន្តែខ្ញុំដឹងថាវាកើតឡើង។ ខ្ញុំមិនអាចមើលឃើញពីរបៀបដែលព្រះអាចធ្វើការទាំងនេះទេ។ វាមិនមែនជាអាជីវកម្មរបស់ខ្ញុំក្នុងការពន្យល់វាទេ។ គឺទ្រង់ តែប៉ុណ្ណោះ។ ទ្រង់ជាអេឡូហ៊ីម ជាអ្នកដែលមានគ្រប់ទាំងអស់ដោយអង្គទ្រង់ផ្ទាល់។ ខ្ញុំគ្រាន់តែជាអ្នកបំរើរបស់ទ្រង់ប៉ុណ្ណោះ។ ខ្ញុំដឹងថាទ្រង់បានសន្យា ហើយខ្ញុំដឹងថាវានៅទីនេះ។ នោះជារឿងមួយដែលខ្ញុំដឹង។ ខ្ញុំដឹងថា ទ្រង់គឺនៅដដែលដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ

និងជារៀងរហូត។ ខ្ញុំដឹងថាទ្រង់បានសន្យានឹងការនេះ ហើយព្រះគឺនៅទីនេះដើម្បីធ្វើឱ្យការសន្យារបស់ទ្រង់ពិត។ បាទ។ ផ្លូវដែលព្រះប្រទាន!

68 អ៊ីស្រាអែលត្រូវបានផ្តល់ឱ្យមានហោរាម្នាក់ ដែលបានបញ្ជាក់ព្រះបន្ទូល ហើយគេត្រូវបាននាំចេញក្រៅ។ ហោរានេះ គឺលោកម៉ូសេ គាត់បានរស់នៅក្នុងទីរហោស្ថានអស់រយៈពេលសែសិបឆ្នាំ តស៊ូជាមួយមនុស្សទាំងនេះ ព្យាយាមរក្សាពួកគេរហូតដល់គាត់អាចនាំពួកគេទៅទឹកដីសន្យា។ មកដល់កន្លែងមួយ បុរសត្រូវស្លាប់ គាត់មានអាយុមួយរយម្ភៃឆ្នាំ។ មិនមានកន្លែងសម្រាប់គាត់ស្លាប់ទេ។ នៅពេលដែលគាត់បានត្រៀមខ្លួនរួចជាស្រេចដើម្បីស្លាប់ ព្រះជាម្ចាស់បានផ្តល់ថ្មដល់គាត់ ថ្មដាដែលគាត់បានវាយនៅទីរហោស្ថាន គឺជាថ្មដែលដើរតាមគេ ដែលគេបានផឹកពីថ្មនោះ។ ព្រះទ្រង់បានប្រទានថ្មមួយដល់គាត់ និងកន្លែងស្លាប់ ដែលម៉ូសេអាចស្លាប់ដោយសមរម្យ។

69 នៅលើថ្មដានេះ ព្រះជាម្ចាស់ អនុញ្ញាតឱ្យខ្ញុំស្លាប់នៅលើថ្មដាដដែលនោះ! នោះហើយជាកន្លែងដែលខ្ញុំចង់ទៅ។ ថ្មដានោះគឺជាព្រះគ្រីស្ទយេស៊ូវ។ បាទមែនហើយ។

70 បន្ទាប់ពីគាត់បានស្លាប់ នៅលើថ្មដានោះ គាត់ត្រូវការអ្នកទ្រដៃជើង។ ព្រះបានបញ្ជូនទេវតាមួយក្រុមមកឯគាត់។ ហេតុអ្វីបានជាមិនមែនពួកចាស់ទុំរបស់គាត់? ព្រោះគ្មានអ្នកណាអាចយកគាត់ទៅទីណាបានទេ មានតែទេវតា។ ពួកគេបានដាក់គាត់ចូលទៅក្នុងវត្តមានរបស់ព្រះ គាត់ត្រូវការអ្នកទ្រ ហើយព្រះក៏បានប្រទានវាមក។ គាត់បានទៅតាមផ្លូវដែលព្រះបានប្រទាន។ ហាលេលូយ៉ា!

71 ហេណុកបានដើរជាមួយព្រះប្រាំរយឆ្នាំ ហើយគាត់ជាទីពេញចិត្តនឹងទ្រង់។ គាត់ត្រូវការផ្លូវខ្ពស់ដើម្បីទៅផ្ទះ។ ព្រះបានផ្តល់វា។

72 អេលីយ៉ាបានដាក់បណ្តាសាយេសេបិលអំពីមុខដែលនាងលាបពណ៌ ហើយវិធីរបស់នាងបានធ្វើឱ្យមនុស្សទាំងអស់ធ្វើដែរ។ ហើយគាត់នឿយហត់និងព្រួយ ហើយត្រៀមសម្រាប់ទៅផ្ទះ។ គាត់ចាស់ណាស់ហើយគាត់មិនអាចដើរឆ្លងកាត់ទន្លេយ័រដាន់បានទេ។ ព្រះបានផ្តល់ផ្លូវសម្រាប់គាត់ឆ្លងទន្លេយ័រដាន់។ គាត់ចង់ឡើងទៅស្ថានសួគ៌ ដើម្បីជួបព្រះជាម្ចាស់។ ព្រះបានចាត់រទេះភ្លើងចុះមក ហើយនិងសេះ ក៏ចាប់គាត់ឡើងទៅ។ ផ្លូវដែលព្រះបានប្រទាន។ ផ្លូវដែលព្រះបាន

ប្រទាន។ ទ្រង់តែងតែធ្វើវាយ៉ាងប្រាកដ។ ត្រូវហើយ។ បាទ មែនហើយ។ ព្រះផ្តល់ផ្លូវ ជានិច្ច។ បាទ។

73 ពួកអ្នកប្រាជ្ញ កាលពួកគេនៅតាមផ្លូវពីក្រុងបាប៊ីឡូន ពួកគេបានឃើញផ្លូវដែលពួកគេចង់ចុះទៅ ព្រោះគេដឹងថាស្តេចអង្គនេះនឹងកើត។ ពួកគេត្រូវការត្រីវិស័យ ព្រះបានផ្តល់ផ្កាយមួយ។ ពួកគេបានបន្សល់ទុកអ្វីៗផ្សេងទៀត។ ពួកគេមិនត្រូវការត្រីវិស័យ ពួកគេបានដើរតាមផ្កាយ។ វាជាផ្លូវដែលព្រះបានប្រទាន។ ព្រះបានផ្តល់ផ្លូវ ពួកគេបានដើរតាមផ្កាយ រហូតដល់ពួកគេបានរកឃើញពន្លឺដ៏ល្អឥតខ្ចោះ។ អូ!

